ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ១០៧/២៤ គ.ជ.ប.ជ.

# របាយការណ៍
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
# ប្រចាំខែមេសា និងទិសដៅខែឧសភា ឆ្នាំ២០២៤

## I. ស្ថានភាពទូទៅ

សភាពការណ៍សកលលោកបានប្រឈមនឹងវិបត្តិសាកលធំៗ ប្លែកៗ គួរឱ្យកត់សម្គាល់ រួមទាំងគ្រោះធម្មជាតិពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ ជម្ងឺរាតត្បាត វិបត្តិខ្វះស្បៀងអាហារ សង្គ្រាមរ៉ាំរ៉ៃដែលបាន និងកំពុងគម្រាមកំហែងដល់សន្តិសុខមនុស្សជាតិ តាមបណ្តាប្រទេសដែលមានខឿនឧស្សាហកម្មជឿនលឿនមួយចំនួនបានជះឥទ្ធិពលជាអវិជ្ជមានដល់សេដ្ឋកិច្ច និងសង្គមជាសកល គួរឱ្យព្រួយបារម្ភ ដែលវិបត្តិនេះ ក៏បានជះឥទ្ធិពលដល់បណ្តាប្រទេសនានា រួមទាំងកម្ពុជាផងដែរ។ ក្នុងស្ថានភាពដ៏លំបាកនេះ ប្រជាពលរដ្ឋ តាមបណ្តាប្រទេសនានាបានប្រឈមនឹងកង្វល់យ៉ាងធ្ងន់ធ្ងរនៃអសន្តិសុខ ក៏ដូចជាភាពស្មុគស្មាញក្នុងជីវភាពរស់នៅ ដែលជាឱកាសឱ្យក្រុមទុច្ចរិតបានប្រើគ្រប់មធ្យោបាយទាញយកផលចំណេញ តាមរយៈការបង្កើតនូវបទល្មើសថ្មីៗ រួមទាំងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ ជាពិសេស ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានដ៏ទំនើប ទាក់ទាញមនុស្សគ្រប់វ័យ គ្រប់ភេទ គ្រប់ស្ថានភាព ឱ្យរងគ្រោះ ក្នុងកលល្បិចដ៏ពិសពុលដើម្បីបម្រើមហិច្ឆតាផលប្រយោជន៍ទុច្ចរិតរបស់ខ្លួនយ៉ាងសាហាវឃោរឃៅ។

ឆ្លៀតក្នុងស្ថានភាពដ៏ប្រឈមនេះ ក្រុមទុច្ចរិត និងបណ្តាញរបស់ខ្លួន បានព្យាយាមរកគ្រប់មធ្យោបាយបង្កើតនូវបទល្មើសថ្មីៗ នៃទាសភាពសម័យទំនើប និងលេចឡើងនូវការកេងប្រវ័ញ្ច និងរំលោភបំពានតាមប្រព័ន្ធអនឡាញ ដោយប្រើប្រាស់បច្ចេកវិទ្យាទំនើប ទាក់ទាញជនរងគ្រោះ ឱ្យធ្លាក់ចូលក្នុងកលល្បិចទុច្ចរិត ដើម្បីបម្រើមហិច្ឆតារបស់ខ្លួន ដែលបង្កឱ្យមានផលប៉ះពាល់យ៉ាងធំធេងលើជនរងគ្រោះ និងជនងាយរងគ្រោះ។

រាជរដ្ឋាភិបាលថ្មី នីតិកាលទី៧នៃរដ្ឋសភា បានបន្តការប្តេជ្ញាចិត្ត យកចិត្តទុកដាក់យ៉ាងខ្លាំងលើកិច្ចការពារថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់ សុខសុវត្ថិភាពនិងសុខុមាលភាពសង្គមឱ្យបានរឹងមាំ ព្រមទាំងការធានានូវសិទ្ធិសេរីភាពគ្រប់យ៉ាងរបស់ពលរដ្ឋ ដោយផ្អែកលើរដ្ឋធម្មនុញ្ញនិងបទបញ្ញត្តិច្បាប់ជាធរមាន។ ឯនៅក្នុងតំបន់ ខិតខំដោះស្រាយបញ្ហា ដោយទន់ភ្លន់បញ្ចៀសការប្រឈមមុខដាក់គ្នា និងការពារភាពរឹងមាំនៃចំណងសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការ។

ជាការឆ្លើយតបចំពោះការប្តេជ្ញាចិត្តខ្ពស់ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជរដ្ឋាភិបាលអណត្តិថ្មីបានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ មុំទី១ (ការបន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ - អទិភាពទី៤) និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឱ្យជីជីវថល។ ក្នុងនោះគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាសេនាធិការ ជូនរាជរដ្ឋាភិបាល ក៏បានការកែសម្រួលរចនាសម្ព័ន្ធរបស់ខ្លួនផងដែរចាប់ពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ និងរៀបចំផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល៥ឆ្នាំ(២០២៤-២០២៨)។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការបង្ការ ទប់ស្កាត់

#### ១. តាមរយៈការលើកកម្ពស់ការយល់ដឹង

##### ១.១. ការអប់រំដោយផ្ទាល់

១.១.១. កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយសាធារណៈ

នៅក្នុងមេសា ឆ្នាំ២០២៤នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរ អង្គភាពពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយច្បាប់ស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម ផ្លូវភេទ ការផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការអនុវត្តគោលនយោបាយ **ភូមិ ឃុំ មានសុវត្ថិភាព** និងការធ្វើវេទិកាសាធារណៈ ផ្សព្វផ្សាយដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ សរុបចំនួន **១៥.៣១៩**លើក មានអ្នកចូលរួមសរុបចំនួន **១.០១១.១៤២**នាក់ ស្ត្រីចំនួន **៤៨៩.៦៨៧**នាក់ (ធៀបនឹងខែមីនា ចំនួន **១.០៦៨.២០៤**នាក់ គឺថយចុះចំនួន **៥៧.០៦២**នាក់ ស្មើនឹង **៥,៣៤%**) ដូចមានតារាងលម្អិតខាងក្រោម៖

តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន / រាជធានី-ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួនដង/លើក | ចំនួនមនុស្ស | ចំនួនស្ត្រី | ចំនួនដង/លើក | ចំនួនមនុស្ស | ចំនួនស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ១.៣៣០ | ៧៧.៤៩៨ | ៣៩.៨០៧ | ៥៧០ | ៤១.៥៥៣ | ១៨.១១៣ |
| | សរុប ក្រសួង ស្ថាប័ន | ១.៣៣០លើក | ៧៧.៤៩៨នាក់ | ៣៩.៨០៧នាក់ | ៥៧០លើក | ៤១.៥៥៣នាក់ | ១៨.១១៣នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | ៤៧ | ២.១៨២ | ១.២៣៧ |
| ២ | ខេត្តកណ្តាល | ១.៤៥៣ | ១០១.៥៣៨ | ៥១.២២៧ | ១.២៣៧ | ៤៧.៧៥០ | ២៣.៨៣៥ |
| ៣ | ខេត្តបាត់ដំបង | ៨៩៣ | ៤៤.៤៥០ | ២៣.៦៨៩ | ៦២៦ | ២០.៥៧៤ | ១១.៥៤៧ |
| ៤ | ខេត្តពោធិ៍សាត់ | ៤៣៣ | ៧០.០៣៦ | ៣៤.៦៥៣ | ១៨៦ | ៧.២៤២ | ៣.៤៦៤ |
| ៥ | ខេត្តសៀមរាប | ៣៦៩ | ៣១.៦៧៩ | ២០.៥២៣ | ២៦៧ | ៨.៣១១ | ៦.៥១៦ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៦៨៣ | ១៩.៩០៥ | ១០.៤៩១ | ៣៣២ | ១១.០២៣ | ៥.៥០៣ |
| ៧ | ខេត្តកំពង់ចាម | ១.៧១៣ | ៩២.៧២៧ | ៤៧.៧៩៥ | ៩៦ | ៦.៣៨៦ | ៣.៩១០ |
| ៨ | ខេត្តព្រះសីហនុ | ១២៤ | ៣.៨៦៨ | ១.៧៥៥ | ៦ | ២១៩ | ៩៩ |
| ៩ | ខេត្តព្រះវិហារ | ២១ | ៣.២៧៨ | ១.៧៧២ | | | |
| ១០ | ខេត្តស្វាយរៀង | ៣៩៨ | ១៧.៦២៨ | ៨.៩២៤ | ២៥៣ | ១២.៨៣៩ | ៧.០២៧ |
| ១១ | ខេត្តប៉ៃលិន | ៤៤ | ១៥៤១ | ៧១១ | | | |
| ១២ | ខេត្តកោះកុង | ២៩២ | ៦.៣៣៣ | ៣.០៨៦ | ១៤៣ | ២.៨៧២ | ១.៤៩១ |
| ១៣ | ខេត្តកំពត | ៣០ | ៤៥០ | ២៥០ | ១៥ | ៥៦០ | ៣៥០ |
| ១៤ | ខេត្តកំពង់ធំ | ៦៧៥ | ២១.០២១០ | ៨៣.៦៥៦ | ១០៨ | ៤២៥៩ | ២.៣៧៨ |
| ១៥ | ខេត្តតាកែវ | ៥៧២ | ៣៣.៩៦៥ | ១២.៦៤៦ | ១០៥ | ៣.៩៦៩ | ១.៨៤០ |
| ១៦ | ខេត្តក្រចេះ | ១៨ | ១៤៣៧ | ៨០៤ | | | |
| ១៧ | ខេត្តកែប | | | | | | |
| ១៨ | ខេត្តកំពង់ស្ពឺ | ៥៤០ | ១១.៨៥៩ | ៥.៦៨៩ | | | |
| ១៩ | ខេត្តស្ទឹងត្រែង | ១ | ៨៣៥ | ៤៩៣ | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | ៦៧៣ | ៥៦.៨៧០ | ២៩.៥៥១ | ៤០០ | ៣១.៨៥២ | ១២.៧៥៨ |
| ២២ | ខេត្តត្បូងឃ្មុំ | ១៩៦ | ៦.២៣៩ | ៣.២១៦ | ៦ | ៤៥៤ | ៧៧ |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | ១៥៦ | ៦.៤៨៩ | ៣.៦៣៨ | ១៣ | ៤៤៤ | ២៧៥ |
| ២៥ | ខេត្តមណ្ឌលគិរី | ១៦ | ៦៩៦ | ៣៧០ | ២៧៩ | ៩.១២២ | ៤.៥២១ |
| សរុប រាជធានី-ខេត្ត | | ៩.៣០០លើក | ៧២២.០៣៣នាក់ | ៣៤៤.៩៣៩នាក់ | ៤.១១៩លើក | ១៧០.០៥៨នាក់ | ៨៦។៨២៨នាក់ |
| សរុបរួម | | ១៥.៣១៩លើក | | ១.០១១.១៤២នាក់ | | ៤៨៩.៦៨៧នាក់ | |

### ១.១.២. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- **ខេត្តកំពត៖**

  - ផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន **០១**លើក អ្នកចូលរួមចំនួន **១៥១**នាក់ (ស្រី **៣៨**នាក់)។

  - ផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ក្នុងកិច្ចប្រជុំ គ ក ស ក ចំនួន **២៨**លើក អ្នកចូលរួមចំនួន **២៧៥**នាក់ (ស្រី **១៧៧**នាក់)។

- **ខេត្តប៉ៃលិន៖** មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ផ្សព្វផ្សាយ ស្តីពីការជួញដូរមនុស្ស ការឆបោកតាមប្រព័ន្ធអនឡាញ និងការធ្វើចំណាកស្រុកដោយខុសច្បាប់ ក្នុងកិច្ចប្រជុំជាមួយការិយាល័យជំនាញ និងគណៈគ្រប់គ្រងសាលារៀន ដើម្បីការអនុវត្តការងារសាលារៀនស្តង់ដាគំរូ អ្នកចូលរួមចំនួន **៧០**នាក់ (ស្រី **២០**នាក់)។

- **ខេត្តព្រះវិហារ៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ផ្សព្វផ្សាយ និងចុះជំរុញការជ្រើសរើសសិស្សឱ្យចូលរៀនជំនាញបច្ចេកទេសវិជ្ជាជីវៈ និងបានបញ្ជ្រាបអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាជននៅតាមបណ្តាខ្នងផ្ទះ នៅស្រុកសង្គមថ្មី និងស្រុករវៀង ចំនួន **០២**លើក អ្នកចូលរួមចំនួន **២៦៤**នាក់ (ស្រី **១៣២**នាក់)។

### ១.១.៣. ការផ្សព្វផ្សាយរបស់អង្គការដៃគូ

- **ខេត្តបាត់ដំបង៖** អង្គការសាម៉ារីតាន់ភឺស

  - ធ្វើយុទ្ធនាការសម្តែងរឿងអប់រំខ្លីរបស់យុវជន និងយុវនារីដល់យុវជន និងអាណាព្យាបាលយុវជន និងសហគមន៍ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ទប់ស្កាត់ការជួញដូរមនុស្ស អំពើហិង្សាលើយេនឌ័រ បាន **០៤**កន្លែង គឺ នៅវិទ្យាល័យសំពៅលូន អនុវិទ្យាល័យចំបក់ អនុវិទ្យាល័យកូនភ្នំ៣២ និងភូមិអូរកាច់ សរុបចំនួន **១.០២៤**នាក់។

  - បានធ្វើយុទ្ធនាការប្រមូលយុវជនលេងកីឡា ដើម្បីបញ្ជ្រាបសារអប់រំពីការចំណាកស្រុកដោយសុវត្ថិភាព ទប់ស្កាត់ការជួញដូរមនុស្ស អំពើហិង្សាលើយេនឌ័រ បាន**០២**កន្លែង គឺ នៅវិទ្យាល័យសំពៅលូន និងអនុវិទ្យាល័យឈើទាល សរុបចំនួន **២៤៣**នាក់។

  - ផ្សព្វផ្សាយបន្តអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់អ្នកស្ម័គ្រចិត្តភូមិ និងយុវជនស្ម័គ្រចិត្តក្នុងការផ្សព្វផ្សាយបន្ត នូវមេរៀនពីការចំណាកស្រុកដោយសុវត្ថិភាពតាមខ្នងផ្ទះ និងយុវជនតាមសាលារៀន សរុបចំនួន **៤.៧៩៥**នាក់។

- **ខេត្តសៀមរាប៖** អង្គការមូលនិធិអេ២១ ផ្សព្វផ្សាយបង្ការទប់ស្កាត់ ស្តីពីអំពើជួញដូរមនុស្ស និងសុវត្ថិភាព កុមារតាមប្រព័ន្ធអនឡាញ ដល់សិស្សានុសិស្សនៅក្នុងក្រុងសៀមរាប និងស្រុកអង្គរធំចំនួន **០៣**លើក អ្នកចូលរួមចំនួន **១០៦**នាក់(ស្រី **៥០**នាក់)។

### ១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

• ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ផ្សព្វផ្សាយតាមរយៈផេកហ្វេសប៊ុក មានអ្នកចូលទស្សនាចំនួន ១.៦២០ដង។

• **ខេត្តត្បូងឃ្មុំ៖** មន្ទីរព័ត៌មានខេត្ត ផ្សព្វផ្សាយតាមវិទ្យុជាតិ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាពចំនួន ៦០លើក។

• **ខេត្តសៀមរាប៖** មន្ទីរព័ត៌មានខេត្ត ផ្សព្វផ្សាយតាមវិទ្យុនគរភ្នំ និងទូរទស្សន៍ជាតិ ស្តីពីកិច្ចការពារជនរងគ្រោះ វិធានការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត ការស្វែងរកការងារធ្វើក្នុងស្រុក ការស្វែងរកជំនួយពីអាជ្ញាធរ និងអង្គការសង្គមស៊ីវិលចំនួន ១១៧លើក។

• **ខេត្តប៉ៃលិន៖** មន្ទីរព័ត៌មានខេត្ត ផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាពចំនួន ២៤៨លើក។

• **ខេត្តព្រៃវែង៖** មន្ទីរព័ត៌មានខេត្ត ផ្សព្វផ្សាយសារអប់រំ នៃការជួញដូរមនុស្ស តាមវិទ្យុបារាយណ៍អណ្តែត ចំនួន ៥០លើក។

### ១.៣. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ

• **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយសក្នុងកម្មវិធីសន្ទនាមតិ«ជីវិតយើង សង្គមយើង» នៃវិទ្យុជាតិកម្ពុជា និងវិទ្យុវត្តភ្នំ ពិភាក្សានូវប្រធានបទ «ទប់ស្កាត់អំពើជួញដូរមនុស្ស និងកិច្ចគាំពារពលករនៅក្រៅប្រទេស»។

• **ខេត្តសៀមរាប៖** តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមជាវាគ្មិនក្នុងកម្មវិធីយើងធ្វើបាន ស្តីពីការទប់ស្កាត់អំពើកេងប្រវ័ញ្ចពលកម្មលើកុមារ និងកិច្ចគាំពារកុមារ។

### ១.៤. ការផ្សព្វផ្សាយតាមរយៈឧបករណ៍ (IEC)

• **ខេត្តបាត់ដំបង៖** អង្គការសាម៉ារីតាន់ភីស បានចែកខិត្តប័ណ្ណផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ៤.០៨២សន្លឹក ទប់ស្កាត់ការជួញដូរមនុស្ស ២.៨១៥សន្លឹក ការពារការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញ ២.០៨២សន្លឹក និងផ្លិតប្លាស្ទីកពីសារចំណាកស្រុកដោយសុវត្ថិភាព ២.៩៦៨សន្លឹក។

• **ខេត្តសៀមរាប៖**

- រដ្ឋបាលស្រុកពួក បានធ្វើការចែកខិតប័ណ្ណព័ត៌មាន ស្តីពីការធ្វើចំណាកស្រុក និងការស្វែងរកជំនួយចំនួន ៣.១៧៩ខិតប័ណ្ណ។

- អង្គការមូលនិធិអេ២១ បានចុះចែកចាយសម្ភារៈទប់ស្កាត់ការកេងប្រវ័ញ្ចលើកុមារ និងអំពើជួញដូរមនុស្ស ចំនួន ០៤លើក អ្នកចូលរួមចំនួន ៩១០នាក់ (ស្រី ៥២១នាក់)។

## ២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ២.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

• ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេសទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន ១៩១.៥២៨នាក់(ស្រី ៨៦.៥៣៩នាក់) អនីតិជន ៣.៤៤២នាក់ (ស្រី ១.២៣៣នាក់) ៖

- ស្របច្បាប់ ១៤៩.៨៥២នាក់(ស្រី៧០.១៥៦នាក់) អនីតិជន៤៦៩នាក់(ស្រី១៧៩នាក់)។
- មិនស្របច្បាប់ ៤១.០១១នាក់(ស្រី១៦.០៩៧នាក់) អនីតិជន២.៨៤៣នាក់(ស្រី១.០១៩នាក់)។

- ជាប់ការទាក់ទង ៦៦៦នាក់(ស្រី២៨៥នាក់) អនីតិជន១៣០នាក់ (ស្រី៣៥នាក់)។

• ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់មកវិញដោយខ្លួនឯង ពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ ចំនួន ១៩.២៣៣នាក់(ស្រី៧.៨៨៣នាក់) អនីតិជន២៥១នាក់ (ស្រី៩៦នាក់)។

• **ខេត្តបាត់ដំបង៖** កម្លាំងនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្ត សហការជាមួយកម្លាំងជំនាញ នៃអធិការដ្ឋាននគរបាលស្រុកទាំង៤ជាប់ព្រំដែន បានទប់ស្កាត់ពលករខ្មែរបាន ០១លើក ដោយធ្វើការអប់រំពលករ ០២នាក់ និងបញ្ជូនពួកគាត់ទៅលំនៅដ្ឋានវិញ។

**២.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ**

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ**

• កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប និងខេត្តកែប បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញាកម្ម ដល់ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន ៤៩គោលដៅ មនុស្សចំនួន ៣១៥នាក់(ស្រី ២២៩នាក់)។

• កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង កោះកុង និងព្រះវិហារ បានល្បាតឃ្លាំមើលគោលដៅសង្ស័យ មានសកម្មភាពអាជីវកម្មផ្លូវភេទ ចំនួន ២៦លើក។

**២.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

▪ **ក្រសួងមហាផ្ទៃ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចំនួន ១៦២នាក់(ស្រី ១៥៦នាក់) មាន ១៣សញ្ជាតិ រួមមាន៖ ចិន ៩១នាក់ អាមេរិក ២៨នាក់(ស្រី០១នាក់) កូរ៉េខាងត្បូង ២៦នាក់(ស្រី០៣នាក) បារាំង ០៤នាក់ ឥណ្ឌូនេស៊ី ០៣នាក់(ស្រី០១នាក់) អូស្ត្រាលី ០២នាក់ កាណាដា ០២នាក់(ស្រី០១នាក ទួគី ០១នាក់ វៀតណាម ០១នាក់ បែលហ្សិក ០១នាក់ នីហ្សេរីយ៉ា ០១នាក់ ហូឡង់ ០១នាក់ និងប៉ូឡូញ ០១នាក់។

**៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

• **ខេត្តព្រះសីហនុ៖** ផ្នែកការពារសុវត្ថិភាពកុមារ អង្គការម្លប់តាប៉ាង បានដាក់បណ្តាញម៉ូតូឌុប និងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្តាញតាមសហគមន៍ ផ្នែកភ្នាក់ងារទេសចរណ៍ សរុបចំនួន ១.១៣៣នាក់។

• **ខេត្តបាត់ដំបង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានរៀបចំវគ្គផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការទប់ស្កាត់ពលកម្មកុមារ ក្នុងវិស័យផលិតឥដ្ឋ នៅស្រុកមោងឫស្សី និងថ្មគោល អ្នកចូលរួមចំនួន ៥០នាក់ (ស្រី ១៦នាក់)។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ១៣ករណី លើ១៧ករណី ថយចុះចំនួន ០៤ករណី ស្មើនឹង ២៣,៥២% ...

- ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្តចំនួន ១៧នាក់(ស្រី ០៣នាក់)។
- សង្គ្រោះជនរងគ្រោះចំនួន ៣៥នាក់(ស្រី ២២នាក់) អាយុក្រោម១៥ឆ្នាំ ០៩នាក់ អាយុ១៥-១៧ឆ្នាំ ០៧នាក់ និងអាយុ១៨ឆ្នាំឡើង ១៩នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ១០នាក់ ប្រគល់ឱ្យអន្តោប្រវេសន៍ ១១នាក់ និងប្រគល់ឱ្យគ្រួសារ ១៤នាក់) ក្នុងនោះចែកជា៖

### ១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ០៥ករណី/០៥ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ០៨នាក់ (ស្រី ០១នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ១៩នាក់ អាយុក្រោម១៥ឆ្នាំ ០១នាក់ អាយុ១៥-១៧ឆ្នាំ ០១នាក់ និងអាយុ១៨ឆ្នាំឡើង ១៧នាក់ (ប្រគល់ឱ្យអន្តោប្រវេសន៍ ១១នាក់ និងប្រគល់ឱ្យគ្រួសារ ០៨នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០២ | ០៧ | ០៣ |
| -អំពើលក់ដូរមនុស្ស | ០១ | ០១ | ០២ |
| -ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០២ | ១១ | ០៣ |
| *សរុប* | *០៥ ករណី* | *១៩ នាក់* | *០៨ នាក់* |

### ២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ០៨ករណី/១២ករណី (ថយចុះ ០៤ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០៩នាក់ (ស្រី ០២នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ១៦នាក់(ស្រី១៥នាក់) អាយុក្រោម១៥ឆ្នាំ ០៨នាក់ អាយុ១៥-១៧ឆ្នាំ ០៦នាក់ និងអាយុ១៨ឆ្នាំឡើង ០២នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ១០នាក់ និងប្រគល់ឱ្យគ្រួសារ ០៦នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -សញ្ចារកម្ម | ០១ | ០១ | ០១ |
| -សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០១ | ០៩ | ០១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៦ | ០៦ | ០៧ |
| *សរុប* | *០៨ ករណី* | *១៦ នាក់* | *០៩ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា
  - នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលបានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសចិនចំនួន ២៣នាក់(ស្ត្រី) ជាករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ ១៣នាក់ និងងាយរងគ្រោះ ១០នាក់។

• មណ្ឌលសំចតប៉ោយប៉ែត៖

- ទទួលពលករចំណាកស្រុក ដែលបញ្ជូនត្រឡប់ពីប្រទេសថៃចំនួន ៧៨២នាក់ (ស្ត្រី ២៣២នាក់ បុរស ៤៩៧នាក់ កុមារី ២៣នាក់ កុមារា ៣០នាក់) បានកំណត់អត្តសញ្ញាណបឋមរកឃើញករណីងាយរងគ្រោះ ០១នាក់ និងជនរងគ្រោះដោយអំពើជួញដូរមនុស្ស ០៣នាក់(ស្ត្រី ០២នាក់)។

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ**

• **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** បានទទួល និងសម្ភាសន៍ពលរដ្ឋខ្មែរ ដែលបញ្ជូនត្រឡប់ពីប្រទេសចិនចំនួន ០៨នាក់(ស្រី) ជាលទ្ធផលរកឃើញជនរងគ្រោះដោយអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ ០៥នាក់ ទៅធ្វើការដោយខុសច្បាប់ ០១នាក់ និងស្នាក់នៅដោយខុសច្បាប់ ០២នាក់។

• **កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្ត** បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរថៃ និងវៀតណាមបញ្ជូនត្រឡប់មកវិញចំនួន ៥៥លើក មនុស្សចំនួន ៩០១នាក់(ស្រី២៨៨នាក់) កុមារ ៤២នាក់ (កុមារី១៦នាក់) ក្នុងនោះមាន៖

- ខេត្តបន្ទាយមានជ័យចំនួន ៤៤លើក មនុស្ស ៨២៩នាក់(ស្រី ២៤៨នាក់)។
- ខេត្តស្វាយរៀងចំនួន ០១លើក មនុស្ស ៥០នាក់(ស្រី ២៨នាក់) កុមារ ៤២នាក់(កុមារី ១៦នាក់)។
- ខេត្តកោះកុងចំនួន ១០លើក មនុស្ស ២២នាក់(ស្រី០៦នាក់)។

### ឃ.២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលសេវាស្នាក់នៅ និងការស្តារនីតិសម្បទា សរុបចំនួន ២២នាក់ (ស្ត្រី ៥៥នាក់) ក្នុងនោះ៖ អង្គការការីតាសកម្ពុជា ១០នាក់(ស្ត្រី ០៣នាក់) អង្គការសួននៃក្តីសង្ឃឹម ០៤នាក់(ស្ត្រី) អង្គការសម្ព័ន្ធចាប់ដៃ ០៣នាក់(ស្ត្រី) អង្គការកម្ពុជាដើម្បីស្ត្រីមានវិបត្តិ ០៣នាក់(ស្ត្រី) និងអង្គការអាដហុក ០២នាក់(ស្ត្រី) ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ ១៣នាក់(ស្ត្រី) ជួញដូរកម្លាំងពលកម្ម ០៩នាក់(ស្ត្រី ០២នាក់)។

### ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះ

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការមូលនិធិហាការអន្តរជាតិ បានធ្វើសមាហរណកម្មស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស ០១នាក់ ទៅសហគមន៍វិញ។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការងារបណ្តុះបណ្តាល

| ល.រ | សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | ចំនួនរួម | ចំនួនស្រី |
|---|---|---|---|---|
| ១ | អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សហការរៀបចំដោយលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តបាត់ដំបង បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដោយមានការឧបត្ថម្ភគាំទ្រដោយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM)៖ | ០១ | ២៩ | ០៨ |

| | | | | |
|---|---|---|---|---|
| ២ | **ខេត្តស្វាយរៀង៖** -មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រុមហ៊ុនចំនួន០៦ បើកវគ្គបណ្តុះបណ្តាលដោយបានបញ្ជ្រាបការយល់ដឹងអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព រួមបញ្ចូលជាមួយនូវប្រធានបទស្តីពីបំនិនជីវិត អាហារូបត្ថម្ភ គ្រឿងញៀន និងសុវត្ថិភាពចរាចរណ៍ ការគ្រប់គ្រងសារជាតុគីមី ភាពជាអ្នកដឹកនាំក្រុមល្អ ដើម្បីបង្កើនផលិតភាពផលិតផល ច្បាប់ស្តីពីការងារ សុខភាព និងសុវត្ថិភាពការងារ និងការជួយសង្គ្រោះបឋម។ | ១២ | ១៩១ | ៨៧ |
| ៣ | **ខេត្តសៀមរាប៖** អង្គការមូលនិធិអេ២១ បានបើកវគ្គបណ្តុះបណ្តាល ស្តីពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ ដល់យុវជន និងម្តាយថែទាំជំនួស របស់អង្គការ SOS ក្រុងសៀមរាប។ | ០២ | ៤០ | ២៦ |
| ៤ | **ខេត្តក្រចេះ៖** ស្នងការដ្ឋាននគរបាលខេត្ត បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការបង្ការទប់ស្កាត់ការលួចនាំមនុស្សឆ្លងដែនដោយខុសច្បាប់ និងការជួញដូរមនុស្សគ្រប់ទម្រង់ ដល់នាយ-នាយរងនគរបាល និងមន្ត្រីនៃស្នងការដ្ឋាននគរបាលខេត្ត ក្រោមអធិបតីភាព ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** អគ្គស្នងការរងនគរបាលជាតិ។ | ០១ | ១៥៣ | ១៦ |
| ៥ | **ខេត្តព្រះវិហារ៖** ស្នងការដ្ឋាននគរបាលខេត្ត បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការបង្ការទប់ស្កាត់ការលួចនាំមនុស្សឆ្លងដែនដោយខុសច្បាប់ និងការជួញដូរមនុស្សគ្រប់ទម្រង់ ក្រោមអធិបតីភាព ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** អគ្គស្នងការរងនគរបាលជាតិ។ | ០១ | ១០០ | ១១ |
| | សរុប | **១៧ លើក** | **៥១៣ នាក់** | **១៤៨ នាក់** |

### ក.២. សិក្ខាសាលា

- **ខេត្តត្បូងឃ្មុំ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំង ស្តីពីកិច្ចសហការ ការបង្ការទប់ស្កាត់ ការប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្សគ្រប់ទម្រង់ និងការធ្វើចំណាកស្រុកមិនស្របច្បាប់ជាមួយអ្នកពាក់ព័ន្ធ ក្រោមអធិបតីភាព លោកជំទាវ ឧត្តមសេនីយ៍ឯកវេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ប.ជ.ប និងលោកជំទាវ **នី ចាន់ធីតា** អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ ព្រមទាំងវត្តមានចូលរួមពីលោកនាយកប្រចាំប្រទេសអង្គការសម្ព័ន្ធចាប់ដៃ លោកស្រីនាយករងរដ្ឋបាលសាលាខេត្ត តំណាងអភិបាលក្រុង-ស្រុក តំណាងស្នងការនៃស្នងការដ្ឋាន តំណាងមន្ទីរអង្គភាពពាក់ព័ន្ធ ជនបង្គោលគម្រោងឆ្លុះបញ្ចាំងការងារផ្សព្វផ្សាយការងារសហគមន៍ សរុបចំនួន **៧០**នាក់ (ស្រី ៤៤នាក់)។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. កិច្ចប្រជុំក្នុងប្រទេស និងក្រៅប្រទេស

#### ខ.១.១ កិច្ចប្រជុំក្នុងប្រទេស

- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**

- បានរៀបចំកិច្ចប្រជុំពិភាក្សាផ្ទៃក្នុង លើការងារសវនកម្មផ្ទៃក្នុង ការគ្រប់គ្រងបុគ្គលិក ការពិនិត្យលើកម្លាំងជាក់ស្តែង ដែលមានសៀវភៅបុគ្គលិក រចនាសម្ព័ន្ធរបស់អង្គភាពមួយៗ ធ្វើសៀវភៅផែនការរបស់ក្រុមការងារនីមួយៗ ដោយដកស្រង់ចេញពីផែនការរយៈពេល៥ឆ្នាំ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។

- បានបើកកិច្ចប្រជុំពិភាក្សាលម្អិតអំពីតួនាទី ភារកិច្ចរបស់មន្ត្រីជំនួយការនៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។

- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំប្រតិភូរាជរដ្ឋាភិបាល ដើម្បីចូលរួមកិច្ចប្រជុំផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រ ស្តីពីការលើកកម្ពស់ ការគ្រប់គ្រងរដ្ឋបាលដែនដី សន្តិសុខជាតិ សណ្តាប់ធ្នាប់សារធារណៈ និងសុវត្ថិភាពសង្គម ឆ្នាំ២០២៤-២០២៨ របស់ក្រសួងមហាផ្ទៃ សមាសភាពចូលរួមមាន ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ព្រះរាជអាជ្ញារង តំណាងសាលាដំបូងខេត្ត មន្ទីរអង្គភាពចំណុះខេត្ត អភិបាលក្រុង ស្រុក ស្នងការរង អធិការ មេប៉ុស្តិ៍ ចៅសង្កាត់ ទូទាំងខេត្ត សរុបប្រមាណ **៣២៦**រូប នៅសាលប្រជុំសាលាខេត្តកំពង់ឆ្នាំង។

- បានទទួលកិច្ចប្រជុំពិភាក្សា ជាមួយតំណាង ស្ថានទូតឥណ្ឌាប្រចាំនៅកម្ពុជា លើការផ្សព្វផ្សាយព័ត៌មាន អំពីការជាប់គាំងរបស់ប្រជាជនឥណ្ឌា នៅប្រទេសកម្ពុជា តំណាងភាគីរាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងតំណាងភាគីឥណ្ឌា មានលោកជំទាវ បណ្ឌិត Devyani khobragade អគ្គរដ្ឋទូតប្រទេសឥណ្ឌាប្រចាំកម្ពុជា កិច្ចពិភាក្សានេះធ្វើឡើងក្នុងគោលបំណង ដើម្បីពង្រឹងកិច្ចសហការ រវាងសាធារណរដ្ឋឥណ្ឌា និងព្រះរាជាណាចក្រកម្ពុជា ជាច្រើនវិស័យ ក្នុងនោះរួមទាំងកិច្ចសហការវិស័យហោះហើរត្រង់មកកម្ពុជា និងកិច្ចសហការលើវិស័យប្រឆាំងការជួញដូរមនុស្សដែលកម្ពុជា និងឥណ្ឌាមាន MOU ជាមួយគ្នា តាំងពីឆ្នាំ២០១៨មកម្ល៉េះ នៅទីស្តីការក្រសួងមហាផ្ទៃ។

**ខ.១.២ កិច្ចប្រជុំក្រៅប្រទេស**

- **ខេត្តប៉ៃលិន៖** លោកជំទាវ **បាន ស្រីមុំ** អភិបាលខេត្តប៉ៃលិន ឯកឧត្តម **ហុក សុផល** អភិបាលរងខេត្ត និងលោកស្រី **គុំ ចាន់ធារី** នាយករងរដ្ឋបាល អញ្ជើញចូលរួមកិច្ចប្រជុំ រវាងបញ្ជាការដ្ឋានការពារព្រំដែន ចាន់បុរី និងត្រាត និងភូមិភាគទី៥ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការព្រំដែនថ្នាក់តំបន់(RBC) នៅសណ្ឋាគារ New Travel Lodge ខេត្តចាន់បុរី ប្រទេសថៃ។

**ខ.២. ការទទួលជួបពិភាក្សាការងារ**

លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

- បានទទួលជួបពិភាស្សាការងារ និងសំណេះសំណាល ជាមួយអង្គការ អេរិក្ស គោលបំណង គឺដើម្បីអង្គការអេរិក្ស ធ្វើការណែនាំសមាសភាពអង្គការដៃគូ របស់ខ្លួនដែលកំពុងតែអនុវត្តន៍សកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងវិស័យប្រឆាំងការជួញដូរមនុស្ស។
- បានទទួលជួបជាមួយតំណាងខាងអង្គការ Asean-Act ដើម្បីពីភាក្សាការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើបច្ចុប្បន្នភាពការងារកន្លងមក។
- **ខេត្តសៀមរាប៖** លោកស្រីប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលជួបសម្តែងការគួរសមជាមួយអង្គការមូលនិធិអេ២១ និងពិភាក្សាទៅលើការពង្រឹងកិច្ចសហប្រតិបត្តិការរវាងអង្គការ និងលេខាធិការដ្ឋានក្នុងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

**គ. ការងារសម្របសម្រួល**

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ **៣៣**លើក មានអ្នកចូលរួមសរុប **៧៥៤**នាក់(ស្រី**៣៧៩**នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **១៣**លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា **០២**លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត ចំនួន **១៨**លើក។(**ឧបសម្ព័ន្ធ១**)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការផ្ញើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

### គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

### ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែឧសភា ឆ្នាំ ២០២៤

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាង

ទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៨. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

៩. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល។

១០. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬនៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ ...ទី ១៣ កើត... ខែ ...ភទ្របទ... ឆ្នាំ រោង ឆស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ...១៩... ខែ ...មិថុនា... ឆ្នាំ២០២៤

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ-ប៊ុនអេង

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

### តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៣៣លើក) មនុស្សចំនួន ៧៥៤នាក់ (ស្រី ៣៧៩នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ<br>- បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធជាផ្លូវការគម្រោងទំនាក់ទំនងយុវវ័យ (Youth Connection) រៀបចំឡើងដោយអង្គការ ការីតាស់ស្វីស សហការជាមួយអង្គការសម្រេចសុបិន្តកុមារ នៅខេត្តសៀមរាប។<br>- បានអញ្ជើញអធិបតីក្នុងកម្មវិធីបិទវគ្គបណ្តុះបណ្តាល ស្តីពីបែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តបាត់ដំបង។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ<br>- បានអញ្ជើញជាអធិបតីក្នុងកម្មវិធីបើកសិក្ខាសាលាឆ្លុះបញ្ចាំង ស្តីពីកិច្ចសហការ ការបង្ការទប់ស្កាត់ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងធ្វើចំណាកស្រុកមិនស្របច្បាប់ នៅខេត្តត្បូងឃ្មុំ។<br>- បានអញ្ជើញជាអធិបតីក្នុងកម្មផ្សព្វផ្សាយ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ការកេងប្រវ័ញ្ច និងការរំលោភបំពានលើកុមារ ដល់មន្ត្រីជួរមុខតាមមូលដ្ឋាន នៅខេត្តក្រចេះ។<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំត្រីមាសទី១ ស្តីពីការអនុវត្តសកម្មភាពការងារ របស់ក្រុមការងារការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ១៦ច្បាប់ លិខិតចូល ៣២ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ១០ច្បាប់ លិខិតចូល ០៥ច្បាប់។<br>▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**<br>- លោកប្រធានក្រុមជំនួយកិច្ចការ បានចូលរួមក្នុងកម្មវិធីបិទវគ្គបណ្តុះបណ្តាល ស្តីពីបែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តបាត់ដំបង។<br>▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**<br>- ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួមជាគ្រូឧទ្ទេសក្នុងវគ្គបណ្តុះបណ្តាល ស្តីពីបែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តបាត់ដំបង។ |

| | |
|---|---|
| | ▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**<br>ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួម៖<br>- កម្មផ្សព្វផ្សាយ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ការកេងប្រវ័ញ្ច និងការរំលោភបំពានលើកុមារ ដល់មន្ត្រីជួរមុខតាមមូលដ្ឋាន នៅខេត្តក្រចេះ។<br>- កម្មវិធីបើកសិក្ខាសាលាឆ្លុះបញ្ចាំង ស្តីពីកិច្ចសហការ ការបង្ការទប់ស្កាត់ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងការធ្វើចំណាកស្រុកមិនស្របច្បាប់ នៅខេត្តត្បូងឃ្មុំ។<br>- កិច្ចប្រជុំត្រីមាសទី១ ស្តីពីការអនុវត្តសកម្មភាពការងារ របស់ក្រុមការងារការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br>▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**<br>- លោកស្រីអនុប្រធានក្រុម បានចូលរួមកម្មវិធីបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់គ្រប់គ្រងលំហូឯកសាររដ្ឋបាលអេឡិចត្រូនិច(DMS) និងប្រព័ន្ធគ្រប់គ្រងជំនួយការប្រជុំ និងបណ្ណាល័យសាធារណៈ (MDA) នៅសាលប្រជុំអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល។<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**<br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួមកិច្ចប្រជុំផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រ ស្តីពីការលើកកម្ពស់រដ្ឋបាលដែនដីសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមឆ្នាំ២០២៤-២០២៨ របស់ក្រសួងមហាផ្ទៃ នៅខេត្តកំពង់ឆ្នាំង។<br>- លោកអនុប្រធានក្រុមបានចូលរួមក្នុងកម្មវិធីបិទវគ្គបណ្តុះបណ្តាល ស្តីពីបែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តបាត់ដំបង។ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | - បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការការពាររួចពីភាពរងគ្រោះដោយអំពើជួញដូរមនុស្ស នៅខេត្តកំពត។<br>- បានចូលរួមសម្របសម្រួលរៀបចំកិច្ចប្រជុំ (សារាចរណ៍លេខ ០១១ ការងារសមាហរណកម្ម តាមដានជនរងគ្រោះដែលបានស្នាក់នៅមណ្ឌលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងសមាគមន៍) ក្រោមអធិបតីភាព ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ១៨ លើក អ្នកចូលរួមសរុបចំនួន ៧៥៤ នាក់ (ស្រី ៣៧៩ នាក់)** | |
| **ខេត្តកណ្តាល** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធការងារប្រចាំខែមេសា ចំនួន០១លើក អ្នកចូលរួមចំនួន៣១នាក់ ស្រី២៣នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានរៀបចំប្រជុំប្រចាំខែ ចំនួន០៦លើក អ្នកចូលរួមចំនួន១៩១នាក់ ស្រី១០៨នាក់។ |
| **ខេត្តកំពង** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធការងារប្រចាំខែមេសា ចំនួន០១លើក អ្នកចូលរួមចំនួន៣០នាក់ ស្រី១៥នាក់។ |

| | |
|---|---|
| **ខេត្តសៀមរាប** | - ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ស្រុក បានរៀបចំកិច្ចប្រជុំដើម្បីធ្វើការតាមដានត្រួតពិនិត្យ ចំនួន០៤លើក អ្នកចូលរួមចំនួន១២៩នាក់ ស្រី៥២នាក់។<br>- ក្រុមការងារកិច្ចការអនុវត្តច្បាប់ បានសហការជាមួយអង្គការសកម្មភាពដើម្បីកុមារ (APLE) បានរៀបចំកិច្ចប្រជុំពិភាក្សា ស្តីពីការប្រើប្រាស់បន្ទប់កុមារមេត្រី នៅស្នងការដ្ឋាននគរបាលខេត្ត ចំនួន០១លើក អ្នកចូលរួមចំនួ២០នាក់ ស្រី០៩នាក់។ |
| **ខេត្តស្ទឹងត្រែង** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធការងារប្រចាំត្រីមាសទី១ ចំនួន០១លើក អ្នកចូលរួមចំនួន២៩នាក់ ស្រី២៤នាក់។ |
| **ខេត្តព្រះវិហារ** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធការងារប្រចាំត្រីមាសទី១ ចំនួន០១លើក អ្នកចូលរួមចំនួន៤៤នាក់ ស្រី១២នាក់។ |
| **ខេត្តស្វាយរៀង** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធការងារប្រចាំត្រីមាសទី១ ចំនួន០១លើក អ្នកចូលរួមចំនួន៥៧នាក់ ស្រី២៥នាក់។ |
| **ខេត្តកំពង់ស្ពឺ** | - មន្ទីរកិច្ចការនារីខេត្ត បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើរំលោភបំពានផ្លូវភេទចំនួន០២លើក អ្នកចូលរួមចំនួន២២៣នាក់ ស្រី១១១នាក់។ |